Fact Sheet - Khmer

# ការបន្សាំមិនអោយមានកូន

## The Contraceptive Implant

### តើអ្វីទៅជាការបន្សាំមិនអោយមានកូន?



ការបន្សាំមិនអោយមានកូនមានតែនៅក្នុងប្រទេសអូស្រ្តាលីប៉ុណ្ណោះដែលហៅថា Implanon NXT®។ កំណាត់ប្លាស្ទិចតូចដែលមានអរម៉ូន ហៅថា progestogen ដែលត្រូវបានបញ្ចេញដោយយឺតៗដើម្បីការពារអ្នកពីការមាន គត៌។ ការបន្សាំត្រូវបានដាក់បញ្ចូលនៅក្រោមស្បែកតែប៉ុណ្ណោះលើផ្នែកខាងក្នុងនៃដៃខាងលើរបស់អ្នក។ វាត្រូវទុកនៅកន្លែងនោះរយៈពេល 3 ឆ្នាំ ក៏ប៉ុន្តែអាចយកចេញមុន ប្រសិនបើអ្នកជ្រើសរើសធ្វើដូច្នេះ។

### តើវាដំណើរការល្អយ៉ាងដូចម្តេច?

វាជាវិធីសាស្រ្តមួយមានប្រសិទ្ធិភាពបំផុតនៃកិច្ចការពារការមានគត៌ (មានប្រសិទ្ធិភាពច្រើនជាង 99.9%) ។ ថ្នាំខ្លះអាចធ្វើអោយការបន្សាំមានប្រសិទ្ធិភាពតិច ហេតុនេះវាសំខាន់ដើម្បីប្រាប់ វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិការបស់អ្នក ប្រសិនបើអ្នកលេបថ្នាំដទៃផ្សេងទៀត។

### តើនរណាអាចប្រើប្រាស់ការបន្សំបាន?

ស្រ្តីភាគច្រើនបំផុតអាចប្រើការបន្សាំ បាន។ វាល្អសំរាប់ស្រ្តីដែលដឹងថាវាពិបាកដើម្បីចងចាំក្នុងការលេបថ្នាំរៀង រាល់ថ្ងៃ។ ស្រ្តីដែលចង់បានការត្រួត ពិនិត្យកំណើតរយៈពេលយូរដែលធ្វើការបានល្អ ក៏ប៉ុន្តែអាចមានលទ្ធផល បញ្រ្ចាសមកវិញលឿនដែលអាចឃើញវាមានសមស្របទៅនឹងស្រ្តី។ វាអាចត្រូវបញ្ចូលភ្លាមក្រោយពីការផ្តល់កំណើត រួមមាននៅក្នុងស្រ្តីដែលកំពុងបំបៅដោះ។

### តើនរណាមិនគួរប្រើប្រាស់ការបន្សំ?

អ្នកមិនត្រូវប្រើប្រាស់ការបន្សាំទេ ប្រសិនបើអ្នកបានមានមហារីកដោះ ឬឬមានបញ្ហាថ្លើមណាមួយពិតប្រាកដ។
ការបន្សាំអាចមិនសមស្របនឹងអ្នក ប្រសិនបើអ្នកងាយនឹងមានស្លាកស្នាមក្រាស់ (ស្នាមដំបៅដែលពកឡើង)។ ប្រសិនបើអ្នកមិនចង់មានអ្វីនៅក្រោមស្បែករបស់អ្នកទេ ឬប្រសិនបើអ្នកព្រួយបារម្ភពីការមានរដូវមិនប្រក្រតី។

### តើមានផលប៉ះពាល់បន្ទាប់បន្សំឬទេ?

ស្រ្តីខ្លះមានការហូរឈាមមិនប្រក្រតីឬហូរឈាមយូរ។ ការមានរដូវរបស់ពួកគេអាចឈប់ទាំងស្រុង។ ផលប៉ះពាល់បន្ទាប់បន្សំដទៃទៀតគឺកម្រមាន ក៏ប៉ុន្តែស្រ្តីខ្លះអាចឈឺក្បាល មានការប្រែប្រួល អាកប្បកិរិយា ឬមានការឈឺដោះ។

### តើការបន្សាំត្រូវដាក់បញ្ចូលយ៉ាងដូចម្តេច?

វេជ្ជបណ្ឌិតដាក់ផ្លាកសំគាល់តូចមួយនៅលើស្បែក នៅលើផ្នែកខាងក្នុងនៃដៃខាងលើរបស់អ្នក។ គេសំអាតស្បែកជាមួយនឹងថ្នាំសម្លាប់មេរោគ និងចាក់បញ្ចូលថ្នាំស្ពឹកបន្តិច ដែលអាចចុកតិចតួច។ ធ្វើដូច្នេះការបញ្ចូលនឹងមិនមានការឈឺចាប់ទេ។ បន្ទាប់មកការបន្សាំត្រូវបានបញ្ចូលនៅក្រោមស្បែកហើយបង់រុំរបួសតូចមួយត្រូវបានដាក់នៅលើដៃ។ បង់រុំរបួសត្រូវនៅកន្លែងនោះរយៈពេល 24 ម៉ោង។ អាចមានការជាំនិងការឈឺនៅជុំវិញកន្លែងធ្វើការបន្សាំដែលអាចបាត់រហូតដល់មួយសប្តាហ៍។

### តើការបន្សាំត្រូវយកចេញយ៉ាងដូចម្តេច?

វេជ្ជបណ្ឌិតចាក់បញ្ចូលថ្នាំស្ពឹកបន្តិចនៅចុងបញ្ចប់នៃការបន្សាំនិងធ្វើការកាត់ស្បែកតូចមួយ។
នៅចុងបញ្ចប់នៃការបន្សាំអាចត្រូវរុញឆ្លងកាត់ការកាត់តូចមួយ ឬទាញចេញដោយការប្រើប្រាស់ឧបករណ៍តូច មួយ។
ប្រសិទ្ធិភាពនៃការគ្មានកូនត្រូវបានបាត់បង់ភ្លាមនៅពេលដែលការបន្សាំត្រូវបានយកចេញ។ ស្រ្តីច្រើនបំផុតមានរដូវធម្មតានៅក្នុងពេលមួយខែ។ ការបន្សាំត្រូវតែយកចេញក្រោយពេលបីឆ្នាំ។ ការបន្សាំថ្មីអាចត្រូវបញ្ចូលបានភ្លាមនៅពេលដែលការបន្សាំចាស់ត្រូវបានយកចេញ។

### តើខ្ញុំអាចទទួលបានការបន្សាំមិនអោយមានកូននៅកន្លែងណា?

អ្នកត្រូវជួបវេជ្ជបណ្ឌិតដើម្បីទទួលបានក្រដាសសំរាប់ធ្វើការបន្សាំ។ វេជ្ជបណ្ឌិតជាច្រើននឹងនិយាយអំពីការ បន្សាំនៅពេលមកជួបជាលើកដំបូងនិងស្នើរអ្នកអោយត្រឡប់មកវិញម្តងទៀតដើម្បីដាក់វាចូល។ អ្នកអាចមានការ បន្សំដាក់ចូលនៅឯគ្លីនិចផែនការគ្រួសារ ឬដោយវេជ្ជបណ្ឌិតនៅតាមមូលដ្ឋានឬ គិលានុបដ្ឋាយិកាដែលត្រូវបានបណ្តុះបណ្តាលដើម្បីបញ្ចូលវា។

### សំរាប់ពត៌មានថែមទៀត

- *ទាក់ទងផែនការគ្រួសារ NSW តាមខ្សែទូរស័ព្ទនិយាយលេខ 1300 658 886 ឬ មើល www.fpnsw.org.au/talkline*
- *NRS (សំរាប់អ្នកថ្លង់) 133 677*
- *ឬទស្សនាគ្លីនិចផែនការគ្រួសារដែលជិតបំផុតរបស់អ្នក*



ពត៌មាននៅក្នុងក្រដាសអង្គហេតុនេះត្រូវបានផ្តល់ជូនសំរាប់គោលបំណងអប់រំតែប៉ុណ្ណោះ។ FNPNSW បានប្រកាន់យកនូវរាល់ការប្រុងប្រយ័ត្នដើម្បីធានាថាពត៌មានគឺមានភាពត្រឹមត្រូវនិងទាន់សម័យនៅឯពេលវេលានៃការបោះពុម្ពផ្សាយ។ បុគ្គលទាំងឡាយដែលមានការព្រួយបារម្ភអំពីការបន្តពូជផ្ទាល់ខ្លួន ឬ បញ្ហាសុខភាពរួមភេទ ត្រូវបានលើកទឹកចិត្តដើម្បីអោយស្វែងរកដំបូន្មាននិងជំនួយគាំទ្រពីអ្នកផ្តល់ការថែរក្សាសុខភាពរបស់ពួកគេ ឬទស្សនាគ្លីនិចផែនការគ្រួសារ។
ពិនិត្យសើរើឡើងវិញ: ឧសភា 2013/FPNSW 05/13

family planning nsw
Reproductive & Sexual Health

Fact Sheet - English

# THE CONTRACEPTIVE IMPLANT

## What Is The Contraceptive Implant?

The only contraceptive implant available in Australia is called Implanon NXT®. It is a small plastic rod that contains a hormone, called a progestogen, which is slowly released to prevent you from getting pregnant. The implant is inserted just under the skin on the inside of your upper arm. It is left in place for 3 years but can be removed earlier if you choose.



## How Well Does It Work?

It is a very effective method of preventing a pregnancy (more than 99.9% effective). Some medications can make the implant less effective; so it is important to tell your doctor or nurse if you are taking other medications.

## Who Can Use An Implant?

Most women can use an implant. It is good for women who find it hard to remember to take a pill every day. Women who want long-term birth control that works well, but can be reversed quickly can find it suits them. It can be inserted immediately after giving birth, including in women who are breastfeeding.

## Who Should Not Use An Implant?

You should not use an implant if you have had breast cancer or have certain liver problems. The implant may not suit you if you are prone to thickened (keloid) scarring, if you don't want to have something under your skin, or if you are worried about having irregular periods.

## Are There Any Side Effects?

Some women get irregular or prolonged bleeding. Their periods may stop completely. Other side effects are rare, but some women may get headaches, mood changes, or have sore breasts.

## How Is An Implant Inserted?

The doctor puts a small mark on the skin on the inside of your upper arm. They clean the skin with antiseptic, and inject a little anaesthetic, which might sting slightly, so that the insertion will not hurt. Then the implant is inserted just under the skin, and a small bandage is put on the arm. The bandage should stay in place for 24 hours. There may be some bruising and soreness around the implant that can last for up to a week.

## How Is An Implant Removed?

The doctor injects a little anaesthetic just under the end of the implant, and makes a small cut in the skin.

The end of the implant is either pushed through the tiny cut, or pulled out using a small instrument.

The contraceptive effect wears off quickly when the implant is removed. Most women have a normal period within a month. The implant must be removed after three years. A new implant can be inserted as soon as one has been removed.

## Where Can I Get A Contraceptive Implant?

You need to see a doctor to get a script for an implant. Most doctors will talk about it on your first visit and ask you to return for another visit to have it inserted. You can have an implant inserted at a Family Planning clinic or by a local doctor or nurse who has been trained to insert it.

## For Further Information

- Contact the Family Planning NSW Talkline on 1300 658 886 or go to www.fpnsw.org.au/talkline
- NRS (for deaf) 133 677
- Or visit your nearest Family Planning clinic



Family Planning NSW is a not-for-profit organisation funded by the NSW Ministry of Health

The information in this Fact Sheet has been provided for educational purposes only. FNPNSW has taken every care to ensure that the information is accurate and up-to-date at the time of publication. Individuals concerned about any personal reproductive or sexual health issue are encouraged to seek advice and assistance from their health care provider or visit a Family Planning Clinic.
Reviewed May 2014/FPNSW 05/14

family planning nsw
Reproductive & Sexual Health

*Reviewed: June 2014 | FPNSW 06/14*

*The information in this Factsheet has been provided for educational purposes only. Family Planning NSW has taken every care to ensure that the information is accurate and up-to-date at the time of publication. Individuals concerned about any personal reproductive or sexual health issue are encouraged to seek advice and assistance from their health care provider or visit an Family Planning NSW clinic.*